# ផូស៊ីលដើមឈើភ្នំត្បែង (ភូមិក្តី)

*ក្រុមការងារសិក្សាផូស៊ីល នៃនាយកដ្ឋានតំបន់បេតិកភណ្ឌ អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន បានចុះសិក្សាបឋមស្តីអំពីដើមគគីរថ្ម (ផូស៊ីលដើមឈើថ្ម) ដោយបានទទួលព័ត៌មានលោកអ៊ុំសុធីកាលកន្លងទៅ។ ក្នុងខែតុលា ឆ្នាំ២០២១ ក្រុមការងារបានចុះពិនិត្យ ផូស៊ីលដើមឈើថ្ម ស្ថិតនៅភូមិក្តី ឃុំរអាង ស្រុករសង្គមថ្មី ខេត្តព្រះវិហារ ក្នុងភូមិសាស្ត្រតំបន់បេតិកភណ្ឌធម្មជាតិ "ភ្នំត្បែង" (រូបលេខ១)។ ដើម្បីទៅដល់ទីតាំងនេះ គឺត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៦២ ទៅកាន់ខេត្តព្រះវិហារ ដោយបន្តដំណើររហូតដល់ប្រកផ្លូវចូលទៅកាន់ភ្នំត្បែង ត្រង់ចំនុចថ្ម៣ដុំ ស្ថិតក្នុងស្រុកសង្គមថ្មី (រូបលេខ២)។ ភ្នំត្បែងត្រូវបានរាជរដ្ឋាភិបាលដាក់ជាតំបន់ការពារធម្មជាតិ ហៅថាតំបន់បេតកភណ្ឌធម្មជាតិ «ភ្នំត្បែង» តាមអនុក្រឹត្យលេខ១៨៩អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦។ វាមានផ្ទៃដី ២៥២៦៩,៤១ ហិចតា[១] ដែលមានបណ្តោយ៤០គីឡូម៉ែត្រ និងទទឹង១៧គីឡូម៉ែត្រ ដែលមានព្រំប្រទល់ជាប់ក្រុងព្រះវិហារ ស្រុកត្បែង ស្រុកគូលែន ស្រុករវៀង និងស្រុកសង្គមថ្មី។*

*ភ្នំត្បែងជាប្រភេទភ្នំថ្មភក់ បើតាមរយៈផែនទីភូគព្ភសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានកំណត់សំគាល់ដោយអក្សរ* $J_3$ $K_1ss$ *ដែលស្ថិតនៅស័កទី២* (Mesozoic Era) *មានអាយុកាលចន្លោះ ៦៥,៥ ទៅ២៥១លានឆ្នាំ។ បើយោងទៅលើសម័យកាលវិញ គឺស្ថិតនៅចន្លោះសម័យជូរ៉ាស៊ីក* (Jurassic) *និងសម័យក្រេតាស័រ* (Cretaceous)[២] *ដែលមានអាយុចន្លោះពី ៦៥.៥ ទៅ១៩៩.៦លានឆ្នាំ។ គេឃើញថា តំបន់ដែលនៅក្បែរនោះមានទីតាំងដែលជាដីបន្ទុះភ្នំភ្លើង ដែលមានអក្សរសំគាល់* $BN_2$ $Q_1$ *ហើយជាប្រភេទថ្មបាសាល់*[៣] *ដែលកើតឡើងនៅចន្លោះសម័យ* Neogene *និងសម័យ* Quaternary *ក្នុងស័កទី៣* Cenozoic (*អាយុតិចជា៦៥*

[១] *អនុក្រឹត្យ លេខ ១៨៩អនក្រ.បក, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦*

[២] General Department of Mineral Resource, 2010, Geological Map of Cambodia

[៣] General Department of Mineral Resource, 2010, Geological Map of Cambodia

*អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ*

AMS

លានឆ្នាំ)។ តើបាតុភូតទាំងនេះអាចមានទំនាក់ទំនង និងការបម្រែបម្រួលសណ្ឋានដីក្នុងតំបន់នេះឬទេ?

បើយោងតាមរយៈការសិក្សា និងប្រមូលព័ត៌មានបឋម ឃើញថាភ្នំត្បែងមានព័ត៌មានអំពីឈើក្លាយទៅជាថ្មច្រើនទីតាំង ដូចជានៅភ្នំស្រួច អន្ទុងជ្រៅ ក្បែរវត្តតាំងយូរ និងទីតាំងមួយចំនួនទៀតក្រុមការងារមិនទាន់បានទៅដល់នៅឡើយ។ ដោយឡែក ក្នុងអត្ថបទនេះនឹងលើកយកតែផូស៊ីលដើមឈើនៅជើងភ្នំត្បែង ក្នុងភូមិក្តីមកបង្ហាញប៉ុណ្ណោះ។

ផូស៊ីលនៅតំបន់នេះបានលេចចេញដោយទឹកច្រោះ ហើយផូស៊ីលឈើថ្មខ្លះបានបាក់នៅតាមទឹកអូរនោះ។ ផូស៊ីលដែលបានរកឃើញ គឺមានពណ៌ខ្មៅ និងមានត្បូងជាប់ជាមួយផង។ លក្ខណៈរបស់ផូស៊ីលឈើនេះ មានភាពខុសប្លែកពីផូស៊ីលដែលបានរកឃើញកន្លងមក ពីលំផាត់ ស្ទឹងត្រែង ក្រវាញ ភ្នំគូលែន។[២]

នៅក្នុងអូរមានផូស៊ីលឈើជាច្រើនដុំ ដែលបានច្រោះដោយទឹក(រូបលេខ៣-៤) ហើយនៅជាប់នឹងផូស៊ីលទាំងនោះជាត្បូងខ្មៅៗ។ ត្បូងនោះមានលក្ខណៈភ្លឺ និងរឹង ព្រមទាំងមានទំងន់ស្រាល តែវាធូន់ជាងត្បូងបច្ចុប្បន្ន និងល្មមនឹងលិចទឹកបាន។ អ្នកស្រុកហៅត្បូងនេះថា "ត្បូងកប្ប" មានន័យថា ត្បូងដែលមានអាយុកាលយូរមកហើយ (រូបលេខ៥)។ ផូស៊ីលទាំងឡាយនេះកប់ក្នុងស្រទាប់ដីជម្រៅប្រមាណ២០ម៉ែត្រ ប៉ុន្តែគេឃើញមានពីរដើមលេចចេញតាមបណ្តោយច្រាំងអូរ។ ផូស៊ីលឈើនេះ ប្រហែលជាបានភ្លើងឆេះ ឬភ្លើងឆេះព្រៃបន្ទាប់មកកប់ទៅក្នុងដី។ តើវាអាចឆេះដោយសារបន្ទុះភ្នំភ្លើងឬទេ? បំណែកផូស៊ីលដើមឈើថ្មខ្លះមានអង្កត់ផ្ចិតធំជាង៦០ស.ម និងជាប្រភេទដើមឈើផ្សេងៗគ្នា ដូច្នេះតំបន់នេះទំនងជាព្រៃនៅសម័យបុរាណ។ ក្រៅពីនេះ មានកំទេចត្បូងជាប់នៅក្នុងស្រទាប់ដីជាច្រើនផងដែរ(រូបលេខ៦-៧)។ ផូស៊ីលឈើទាំងនេះមិនទាន់អាចកំណត់ប្រភេទនៅឡើយ ដូច្នេះក្រុមការងារនឹងបន្តការសិក្សាបន្ថែមទៀត៕

[២] https://ams.com.kh/khmercivilization

អត្ថបទដោយ៖ លឹម វណ្ណចន្ទ




រូបទី១



រូបលេខ២

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៣



រូបលេខ២៤

អត្ថបទដោយ៖ លឹម វណ្ណចន្ទ



រូបលេខ២៥



រូបលេខ២៦



រូបទី៧

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបទី៨ ទីតាំងចុះសិក្សា

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ លឹម វណ្ណចន្ទ